www.interior.gov.kh

# ពត៌មានប្រចាំថ្ងៃ
# MOI DAILY NEWS

## ពត៌មានប្រចាំថ្ងៃរបស់ក្រសួងមហាផ្ទៃ

**ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០៤**

### ពត៌មានសន្តិសុខសង្គម

-នៅថ្ងៃទី២៧/០៩/២០០៤ វេលាម៉ោង ០៨:៣០នាទី នៅចំណុចវាលស្រែតំបន់ព្រៃកុង ក្នុងភូមិ ស្វាតូច ឃុំគរ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មានជនមិនស្គាល់មុខ បានចងបង្កៃគ្រាប់បែកដាប់នឹងជងធន្លល់របស់ជនរងគ្រោះឈ្មោះ ហុឹម ហ៊ន់ ភេទប្រុស អាយុ៣៥ឆ្នាំ ដែលលាក់ទុកនៅក្រោមដើមឈើ ក្បែរស្រែ បណ្តាលអោយផ្ទុះរបួសជាទម្ងន់ ។ ករណីនេះ សមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវបន្ត ។

-នៅថ្ងៃទី២៧/០៩/២០០៤ សកម្មភាពប្លន់ម៉ូតូអ្នកដំណើរតាមផ្លូវសាធារណ: កើតឡើង០២លើក គឺ :

នៅចំណុចក្រុមទី៨ ភូមិ-សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ និងនៅចំណុចផ្លូវលេខ២៥៧ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក បណ្តាលអោយបាត់ម៉ូតូ០២គ្រឿង ។

-នៅថ្ងៃទី២៧/០៩/២០០៤ វេលាម៉ោង ២០:២០នាទី នៅភូមិ៣ សង្កាត់លេខ១ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ មានជនល្មើស ចំនួន១០នាក់ ប្រដាប់ដោយកាំបិត និងដំបង បានព្រួតគ្នាវាយទៅលើជនរងគ្រោះឈ្មោះ ជិន ថៃ ភេទប្រុស អាយុ៣០ឆ្នាំ (ជនជាតិខ្មែរកម្ពុជាក្រោម) បណ្តាលអោយរងរបួសធ្ងន់ ។ ក្រោយកើតហេតុ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ឃាត់ខ្លួន បានជនល្មើស០៣នាក់ ចំណែក០៧នាក់ទៀតរត់គេចខ្លួន កំលាំងសមត្ថកិច្ចកំពុងស្រាវជ្រាវបន្ត ។

-នៅថ្ងៃទី២៧/០៩/២០០៤ វេលាម៉ោង ២១:១៥នាទី នៅភូមិភ្លង់គោកគ្រើល ឃុំលាងដៃ ស្រុកអង្គរធំ ខេត្ត សៀមរាប មានជនល្មើស ០៤នាក់ ប្រដាប់ដោយអាវុធខ្លី (ផ័រ) ០១ដើម (ក្រម៉ារុំក្បាល) បានចូលប្លន់ផ្ទះប្រជាពលរដ្ឋ ឈ្មោះ ភាន ដេវីត ភេទប្រុស អាយុ៦៤ឆ្នាំ យកបានសំភារ:មាស ប្រាក់មួយចំនួនធំ រួចនាំបក្ខពួកគេចខ្លួនបាត់ ។ ករណីនេះកំលាំងសមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវ ។

-នៅថ្ងៃទី២៦/០៩/២០០៤ វេលាម៉ោង១៨:៣០នាទី នៅចំណុចខាងត្បូងវត្តអង្គស្លី ឃុំឪឡោក ស្រុកអង្គស្នួល ខេត្ត កណ្តាល ជនល្មើសមិនស្គាល់អត្តសញ្ញាណ ០៨នាក់ ប្រដាប់ដោយអាវុធខ្លី០១ដើម ជិះម៉ូតូ០៣គ្រឿង បានស្ទាក់ប្លន់ជនរងគ្រោះ ០២នាក់ (ជិះម៉ូតូឌុបគ្នា) យកបានម៉ូតូ០១គ្រឿង ជិះគេចខ្លួនបាត់ ។ ករណីនេះកំលាំងសមត្ថកិច្ចកំពុងធ្វើការស្រាវជ្រាវ ។

-នៅថ្ងៃទី២៧/០៩/២០០៤ វេលាម៉ោង ០៧:៣០នាទី មានគោយន្ត០១គ្រឿង បើកបរដោយ ឈ្មោះ សំ ដួង ភេទប្រុស អាយុ២០ឆ្នាំ ក្រឡាប់ធ្លាក់ពីលើផ្លូវជាតិលេខ៦ ត្រង់ចំណុចស្ពាន ព្រៃប្រស់ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បណ្តាលអោយរបួសមនុស្ស២១នាក់ (ធ្ងន់១០នាក់) មូលហេតុ អ្នកបើកបរកាច់ចង្កូតជ្រុល ។



អាស័យដ្ឋាន: បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ:៨៥៥-២៣-៧២៦០៥២ Email:webmaster@interior.gov.kh

–នៅថ្ងៃទី២៦/០៩/២០០៤ ប្រជាពលរដ្ឋបានប្រទះឃើញសាកសពមនុស្សប្រុស០១នាក់ មិនស្គាល់ អត្តសញ្ញាណ អណ្តែតទឹកនៅត្រង់ចំណុចប្រឡាយទឹក ហ៊ុន សែន ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល ។ ករណីនេះសមត្ថកិច្ច កំពុងធ្វើការស្រាវជ្រាវ ។

–ប្រជាពលរដ្ឋនៅឃុំសាលាវិស័យ ស្រុកប្រាសាទបល្ល័ង ខេត្តកំពង់ធំ ចូលព្រៃរើសបានអាវុធAK ០១ដើម យកមក ប្រគល់ជូនសមត្ថកិច្ច ។

–នៅរាជធានីភ្នំពេញ កំលាំងសមត្ថកិច្ច បានបង្ក្រាប០១ករណីប្លន់ ឃាត់ខ្លួន០២នាក់, លួច០៤ករណី ឃាត់ខ្លួន ០៥នាក់ ឆក់០១ករណី ឃាត់ខ្លួន០២នាក់ និងករណីបង្ករបួសស្នាម០១ករណី ឃាត់ខ្លួន០១នាក់ ។

–កំលាំងសមត្ថកិច្ចខេត្តកណ្តាល បានបង្ក្រាបករណី លួច ០១ករណី ឃាត់ខ្លួន០២នាក់ និងករណីបង្ករបួសស្នាម ០១ករណី ឃាត់ខ្លួន ០១នាក់ ។

–កំលាំងសមត្ថកិច្ចក្រុងព្រះសីហនុ បានបង្ក្រាបករណី ឃាតកម្ម០១ករណី ឃាត់ខ្លួន០១នាក់, ឆក់០១ករណី ឃាត់ខ្លួន ០១នាក់, បង្ករបួសស្នាម០១ករណី ឃាត់ខ្លួន០៣នាក់ ។

–កំលាំងសមត្ថកិច្ចខេត្តកំពង់ឆ្នាំង បង្ក្រាបបាន០២ករណី ករណីបង្ករបួសស្នាម ឃាត់ខ្លួន០២នាក់ ។

–កំលាំងសមត្ថកិច្ចខេត្តព្រៃវែង បានបង្ក្រាបករណីប្លន់ ០១ករណី ឃាត់ខ្លួន០១នាក់ ។

–កំលាំងសមត្ថកិច្ចខេត្តកំពង់ចាម បានបង្ក្រាបករណីប្លន់ ០១ករណី ឃាត់ខ្លួន០១នាក់ ។

( ប្រភពពត៌មានពីអគ្គស្នងការដ្ឋាននគរបាលជាតិ )



អាស័យដ្ឋាន: បន្ទប់លេខ១១៤ អគារទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ទូរស័ព្ទ/ទូរសារ:៨៥៥-២៣-៧២៦០៥២ Email:webmaster@interior.gov.kh
9/29/2004 4:52 PM